# ការគ្រប់គ្រង
# Payment Elections (ជម្រើសការទូទាត់) របស់អ្នក

ក្នុងនាមជានិយោជិតថ្មី អ្នកនឹងត្រូវបានស្នើសុំឱ្យរៀបចំជម្រើសការទូទាត់ប្រាក់ឈ្នួលរបស់អ្នក។ ការណែនាំខាងក្រោមនឹងជួយអ្នករៀបចំជម្រើសការទូទាត់ប្រាក់ដំបូងរបស់អ្នក ក៏ដូចជាធ្វើការផ្លាស់ប្តូរណាមួយចំពោះវានាពេលអនាគត។

## អ្នកអាចទទួលប្រាក់ឈ្នួលរបស់អ្នកតាមរយៈ៖

- ការដាក់ប្រាក់ដោយផ្ទាល់ (ទៅកាន់គណនីមួយ ឬច្រើន)
- បណ្ណ Wisely Pay ដែលចេញដោយ CDWA
- បណ្ណទូទាត់ប្រាក់ដែលមានស្រាប់
- ឬការរួមបញ្ចូលគ្នានៃការដាក់ប្រាក់ដោយផ្ទាល់ និងបណ្ណទូទាត់ប្រាក់

អ្នកនឹងត្រូវការព័ត៌មានគណនីរបស់អ្នក។ *ព័ត៌មានមិនត្រឹមត្រូវនឹងនាំឱ្យមានការពន្យារពេលក្នុងការទទួលប្រាក់របស់អ្នក។*

## របៀបចូលប្រើ Payment Elections (ជម្រើសការទូទាត់) របស់អ្នក

### ការចូលទៅកាន់ជម្រើសការទូទាត់ប្រាក់របស់អ្នកតាមរយៈកម្មវិធី Pay នៅក្នុង Workday

1. ចូលគណនីទៅក្នុង*វិបផតថល DirectMyCareរបស់ CDWA។*
2. ពីអេក្រង់ My Dashboard របស់ខ្ញុំ សូមចុចប៊ូតុង **Workday** ដើម្បីទៅកាន់គេហទំព័រ Workday របស់អ្នក។
   **ប្រសិនបើអ្នកចូលដល់ទំព័រចូលគណនីហើយ សូមបញ្ចូលឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់ដូចគ្នាដូចដែលធ្លាប់ប្រើដើម្បីចូលទៅក្នុង វិបផតថល DirectMyCare។*
3. ចុចលើ **View All Apps (មើលកម្មវិធីទាំងអស់)**។
4. ចុច **កម្មវិធី Pay**។
5. ចុច **Payment Elections (ជម្រើសការទូទាត់)** នៅក្នុងផ្នែក View/Update Elections (មើល/ធ្វើបច្ចុប្បន្នភាពជម្រើស)។ (រូប. 01)




*រូប. 01*

6. ប្រើប៊ូតុងដើម្បីគ្រប់គ្រងជម្រើសការទូទាត់បច្ចុប្បន្ន។ (រូប. 02)
   - **Edit (កែសម្រួល)៖** ផ្លាស់ប្តូរ / កែតម្រូវព័ត៌មានធនាគារ
   - **Remove (លុបចេញ)៖** លុបព័ត៌មានការដាក់ប្រាក់ដោយផ្ទាល់
   - **View (មើល)៖** មើលព័ត៌មានការដាក់ប្រាក់ដោយផ្ទាល់




*រូប. 02*

### ការចូលប្រើជម្រើសការទូទាត់ប្រាក់របស់អ្នកតាមរយៈកិច្ចការ Onboarding របស់អ្នកនៅក្នុង Workday

ជាផ្នែកនៃកិច្ចការ Onboarding របស់អ្នក អ្នកនឹងត្រូវរៀបចំជម្រើសការទូទាត់របស់អ្នក (ការណែនាំខាងក្រោម)។ ប្រសិនបើអ្នកកំពុងត្រឡប់ទៅកាន់ Payment Elections (ជម្រើសការទូទាត់) ដោយចុចលើកម្មវិធី Pay។ នៅក្នុង Workday អ្នកនឹងអាចចូលប្រើជម្រើសដូចគ្នាដោយចុចប៊ូតុង **Add (បន្ថែម)** ខាងក្រោមព័ត៌មានគណនីរបស់អ្នក។ (រូប. 03)




*រូប. 03*

20250402

*បន្តនៅទំព័របន្ទាប់*

# ការជ្រើសរើសវិធីទូទាត់ (ចាំបាច់)

**វិធីទូទាត់ដែលពេញចិត្ត**

1. នៅក្នុងចន្លោះបំពេញ **Payroll Election Rule (ច្បាប់ជម្រើសបើកប្រាក់ឈ្នួល)** ជ្រើសរើសថាតើអ្នកចង់បាន Direct Deposit (ការដាក់ប្រាក់ដោយផ្ទាល់) (ចំណុចនេះរួមទាំងការដាក់ទៅក្នុងបណ្ណទូទាត់ប្រាក់ដែលមានស្រាប់) (រូប. 04) ឬបណ្ណ Wisely Pay ថ្មី (រូប. 05)។




*រូប. 04*




*រូប. 05*

2. នៅក្នុងចន្លោះបំពេញ **Expense Election Rule (ច្បាប់ជម្រើសនៃការចំណាយ)** សូមជ្រើសរើស **Manual (ដោយផ្ទាល់ដៃ)** សម្រាប់ជម្រើសការទូទាត់ការចំណាយរបស់អ្នក។ (*រូប. 06*)
   - ប្រសិនបើអ្នកជា IP ដែលត្រូវបានអនុញ្ញាតសម្រាប់រយៈចម្ងាយ អ្នកនឹងទទួលបានការទូទាត់សងក្នុងប្រាក់ខែឈ្នួលជាប្រចាំរបស់អ្នក។




*រូប. 06*

## ព័ត៌មានគណនី

3. ប្រសិនបើអ្នកជ្រើសរើស **Direct Deposit (ការដាក់ប្រាក់ដោយផ្ទាល់)** សូមបញ្ចូលព័ត៌មានគណនីរបស់អ្នកនៅក្នុងចន្លោះបំពេញដែលចាំបាច់ដែលបង្ហាញដោយសញ្ញាផ្កាយពណ៌ក្រហម (*)។ (*រូប. 07*) **<u>សូមពិនិត្យគណនី និងព័ត៌មានផ្ទេររបស់អ្នកទ្វេដង។</u>** កំហុសឆ្គងអាចបណ្តាលឱ្យមានការចេញបណ្ណ Wisely Pay។

   **ចំណាំ៖** *ហាមបញ្ចូលសញ្ញាបន្ទាត់ដាច់ៗក្នុងគណនី ឬលេខផ្ទេរ។ វានឹងធ្វើឱ្យព័ត៌មានរបស់អ្នកត្រូវបានបដិសេធ ហើយបណ្ណ Wisely Pay អាចត្រូវបានចេញ។*




*រូប. 07*

4. ប្រសិនបើអ្នកជ្រើសរើស **Wisely Pay Card (បណ្ណ Wisely Pay)** សូមបញ្ចូលព័ត៌មានខាងក្រោមក្នុងចន្លោះបំពេញដែលចាំបាច់ដូចដែលបានបង្ហាញ។ (*រូប. 08*)
   - **លេខផ្ទេរឆ្លងគណនី៖** 071922476
   - **ឈ្មោះធនាគារ៖** Wisely
   - **ប្រភេទគណនី៖** ចរន្ត
   - **លេខគណនី៖** 1

   **ចំណាំ៖** *ទុកពេល 7-10 ថ្ងៃនៃថ្ងៃធ្វើការមុនពេលអ្នកទទួលបានបណ្ណ Wisely Pay របស់អ្នកមកតាមប្រអប់សំបុត្រក្នុងស្រោមសំបុត្រពណ៌សធម្មតា។ ស្រោមសំបុត្រនេះនឹងមានការណែនាំអំពីរបៀបបើកដំណើរការបណ្ណ Wisely Pay របស់អ្នក។*




*រូប. 08*

5. នៅពេលបញ្ចប់ សូមចុច **OK (យល់ព្រម)** ដើម្បីបន្ត។

   **NEXT (បន្ទាប់)៖** អ្នកនឹងមានជម្រើសក្នុងការបែងចែកប្រាក់ឈ្នួល របស់អ្នករវាងគណនី។ ប្រសិនបើមិនបែងចែកប្រាក់ឈ្នួលទេ សូមពិនិត្យមើលព័ត៌មានរបស់អ្នកហើយចុច **Submit (ដាក់បញ្ជូន)**។
   - ប្រសិនបើអ្នកចង់បំបែកប្រាក់បៀវត្សរ៍របស់អ្នករវាងគណនី សូមបន្តជាមួយជំហានបន្ទាប់។

20250402

*បន្តនៅទំព័របន្ទាប់*

# ការបំបែកប្រាក់ឈ្នួលរវាងគណនី (ជាជម្រើស)

អ្នកអាចជ្រើសរើសឱ្យគេដាក់ប្រាក់បៀវត្សរ៍របស់អ្នកចូលទៅក្នុងគណនីច្រើន (គណនីចរន្ត គណនីសន្សំ និង/ឬបណ្ណ Wisely Pay)។ អ្នកអាចបែងចែកការទូទាត់តាមចំនួន ឬភាគរយ។ អ្នកអាចប្រើបណ្ណ Wisely Pay រហូតដល់ចំនួនមួយ និងគណនីធនាគារដាក់ប្រាក់ដោយផ្ទាល់ចំនួនប្រាំមួយ។

ដើម្បីបំបែកការទូទាត់របស់អ្នករវាងគណនីច្រើន អ្នកនឹងត្រូវបញ្ចូលគណនីរបស់អ្នកទាំងអស់ជាមុនសិន។ សូមអនុវត្តតាមជំហានខាងក្រោម៖

1. ចុចប៊ូតុង **Add (បន្ថែម)**។ (*រូប. 09)*
2. បញ្ចូលព័ត៌មានក្នុងចន្លោះបំពេញដែលចាំបាច់។
3. ចុច **OK (យល់ព្រម)**។.
4. ធ្វើជំហានទី 1-3 ម្តងទៀត ប្រសិនបើអ្នកមានគណនីច្រើនទៀត។
5. នៅពេលអ្នកបានបន្ថែមគណនីរបស់អ្នកទាំងអស់រួច សូមចុច **Save (រក្សាទុក)**។

**ចំណាំ៖** *ហាមបញ្ចូលសញ្ញាបន្ទាត់ដាច់ៗក្នុងគណនី ឬលេខផ្ទេរ។ ការធ្វើបែបនេះនឹងធ្វើឱ្យមានការបដិសេធលើព័ត៌មានរបស់អ្នក។*

*សូមពិនិត្យគណនីរបស់អ្នក និងព័ត៌មានផ្ទេរសម្រាប់គណនីនីមួយៗទ្វេដង។ ព័ត៌មានមិនត្រឹមត្រូវនឹងនាំឱ្យមានការពន្យារពេលក្នុងការទទួលប្រាក់របស់អ្នក។*




*រូប. 09*

បន្ទាប់ពីគណនីរបស់អ្នកត្រូវបានបន្ថែម អ្នកនឹងត្រូវកំណត់គណនីទៅ Payroll Election (ជម្រើសបើកប្រាក់ឈ្នួល) របស់អ្នក។

1. នៅក្នុងផ្នែក Payment Elections (ជម្រើសការទូទាត់) សូមចុចប៊ូតុង **Edit (កែសម្រួល)** នៅលើបន្ទាត់ Payroll Election Rule CDWA (CDWA នៃច្បាប់ជម្រើសបើកប្រាក់ឈ្នួល)។ (*រូប. 10*)




*រូប. 10*

2. ចុចប៊ូតុង **+** ដើម្បីបញ្ចូលគណនីបន្ថែមដែលអ្នកបានបង្កើត។ (*រូប. 11)*




*រូប. 11*

3. ចុចចូលទៅក្នុងចន្លោះបំពេញដើម្បីជ្រើសរើសពីបញ្ជីទម្លាក់ចុះសម្រាប់ជម្រើសដូចខាងក្រោម៖
   - **Country (ប្រទេស)** (ជ្រើសរើស - សហរដ្ឋអាមេរិក)
   - **Currency (រូបិយប័ណ្ណ)** (ជ្រើសរើស - USD)
   - **Payment Type (ប្រភេទការទូទាត់)** (ជ្រើសរើស Direct Deposit (ការដាក់ប្រាក់ដោយផ្ទាល់) ឬបណ្ណ Wisely Pay)
   - **Account (គណនី)** (ជ្រើសរើសពីបញ្ជីគណនីដែលអ្នកបានបន្ថែម) (*រូប. 12)*




*រូប. 12*

20250402

*បន្តនៅទំព័របន្ទាប់*

4. នៅក្នុងចន្លោះបំពេញ **Balance/Amount/Percent (សមតុល្យ/បរិមាណ/ភាគរយ)** សូមជ្រើសរើសចំនួនប្រាក់ដុល្លារ ឬភាគរយដែលអ្នកចង់ដាក់ចូលទៅក្នុងគណនីនីមួយៗ។
   - ប្រសិនបើបែងចែកជាភាគរយ ចំនួនសរុបត្រូវតែសរុបចូលគ្នាស្មើនឹង 100%។
   - ប្រសិនបើបែងចែកជាចំនួន គណនីចុងក្រោយត្រូវជ្រើសរើស **Balance (សមតុល្យ)** ដើម្បីរាប់បញ្ចូលចំនួនដែលនៅសល់។ (*រូប. 14*)
   - អ្នកអាចផ្លាស់ប្តូរលំដាប់នៃគណនីដោយចុចសញ្ញាព្រួញ
   - នៅក្នុងក្រឡោន Order (លំដាប់)។ (*រូប. 13*)




*រូប. 13*




*រូប. 14*

5. នៅពេលអ្នកបានបញ្ចប់ <u>សូមពិនិត្យមើលព័ត៌មានទាំងអស់ មុនពេលអ្នកចុច **Submit (ដាក់បញ្ជូន)**</u>។ *ព័ត៌មានមិនត្រឹមត្រូវនឹងនាំឱ្យមានការពន្យារពេលក្នុងការទទួលប្រាក់របស់អ្នក។*
6. អ្នកនឹងត្រូវបាននាំត្រឡប់ទៅអេក្រង់ Manage Payment Elections (គ្រប់គ្រងជម្រើសការទូទាត់)។ ប្រសិនបើអ្នកបានបញ្ចប់ទាំងស្រុងហើយ សូមចុច **Submit (ដាក់បញ្ជូន)**។